16/05/2021



នស/រកត/០៣០៩/២៣២

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ៤ មាត្រា ៧ និងមាត្រា ៩ នៃព្រះរាជក្រឹត្យ
## លេខ នស/រកត/០៨០៤/២៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤
## ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

Media from www.moj.gov.kh

16/05/2021

# ត្រាស់បង្គាប់

**មាត្រា មួយ.-**

មាត្រា ៤ មាត្រា ៧ និងមាត្រា ៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ ត្រូវបានធ្វើការកែសម្រួលដូចតទៅ ÷

**មាត្រា ៤ ថ្មី.-**

គ.ជ.ប.អ មានសមាសភាពដូចតទៅ ÷

- ឥស្សរជនជាន់ខ្ពស់ ០១ រូប ប្រធាន
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប អនុប្រធាន
- ឥស្សរជនជាន់ខ្ពស់ មួយចំនួន អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងផែនការ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១ រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០១ រូប សមាជិក។

សមាសភាពជាក់ស្តែងរបស់ គ.ជ.ប.អ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE

Media from www.moj.gov.kh

មាត្រា ៧ ថ្មី.-

គ.ជ.ប.អ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ និងមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរង មួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

មាត្រា ៩ ថ្មី.-

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.អ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ពីរ.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា បី.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មីនា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត/០៣០៩/២៣៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ : ៥១៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន



Media from www.moj.gov.kh